# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១៤ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្ដីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៩ ស្ដីពី ការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពី ការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពី បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្ដីពី ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០២ ស្ដីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ស្ថិតនៅក្រោមការដឹកនាំ និង ការវាយតម្លៃផ្ទាល់ពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលើដំណើរការនៃការជ្រើសរើសសមាជិកកន្សោមអាទិភាពរបស់ក្រសួង ស្ថាប័ន ឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមនីតិវិធី ព្រមទាំងគោរពបានគោលការណ៍តម្លាភាព និង ការទទួលខុសត្រូវច្បាស់លាស់ ។

**ប្រការ ២.-**

គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- តំណាង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| ២- តំណាង ក្រសួង ស្ថាប័នសាមី | អនុប្រធាន |
| ៣- តំណាង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤- តំណាង ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក ។ |

ការតែងតាំងប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាពត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ៣.-**

សមាជិកគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ដែលមិនបានទទួលប្រាក់បំណាច់មុខងារតាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូឆ្នាំ ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និង តាមមាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃ ទី ២៣ ខែមេសា ឆ្នាំ ២០០២ ស្ដីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ត្រូវបំពេញកិច្ចសន្យាការងារ និងត្រូវបានទទួលប្រាក់ឧបត្ថម្ភទៅតាមលក្ខខណ្ឌ ដូចសមាជិកកន្សោមអាទិភាព ។

**ប្រការ ៤.-**

គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព មានភារកិច្ចចម្បងៗ ដូចខាងក្រោម :

- សិក្សាស្វែងយល់អំពីបេសកកម្មអាទិភាព ព្រមទាំងឯកសារភ្ជាប់នានារបស់ក្រសួង ស្ថាប័ននីមួយៗ ។

- កំណត់លក្ខណៈវិនិច្ឆ័យរួមសម្រាប់ការជ្រើសរើស និងផ្តល់យោបល់លើលក្ខណៈវិនិច្ឆ័យលំអិត ស្របតាមប្រភេទ និង តម្រូវការនៃបេសកកម្ម
- ពិនិត្យបញ្ជីសម្រាំងឈ្មោះបេក្ខជន និងប្រវត្តិរូបដែលបានស្នើឡើង សម្រាប់មុខតំណែងនីមួយៗ
- ធ្វើសម្ភាសបេក្ខជនដែលត្រូវបានស្នើឡើងសម្រាប់មុខតំណែងនីមួយៗនៅក្នុងកន្សោមអាទិភាព ទៅតាមការចាំបាច់
- ផ្តល់ការយល់ព្រមលើបេក្ខភាពនៃបេក្ខជនដែលមានលក្ខណៈសម្បត្តិសមស្រប សម្រាប់មុខតំណែងនីមួយៗ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការជ្រើសរើសសមាជិកកន្សោមអាទិភាព ព្រមទាំងបញ្ជីឈ្មោះបេក្ខជន ជូនក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីពិនិត្យ និង សម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលប្រគល់ជូន ដើម្បីធានាឱ្យដំណើរការនៃការជ្រើសរើសប្រព្រឹត្តទៅបានល្អ ។

## ប្រការ៥. –

សមាជិកនៃគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ។

ប្រធានគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព អាចអញ្ជើញតំណាងគណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព និង តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមសង្កេតការណ៍រាល់ការប្រជុំវាយតម្លៃ និងសម្រេចលើការងារសំខាន់ៗ ។

## ប្រការ៦. –

សមាជិកគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ដែលអវត្តមានមិនបានចូលរួមប្រជុំចំនួន ៣ (បី) ដងជាប់ៗគ្នា ឬ ២/៣ (ពីរភាគបី) នៃការប្រជុំប្រចាំត្រីមាស ដោយគ្មានមូលហេតុ ឬដោយត្រូវបានប្រធានស្ថាប័នចាត់តាំងឱ្យទទួលភារកិច្ចថ្មី ត្រូវផ្លាស់ប្តូរជំនួសវិញដោយសមាជិកមកពីក្រសួង ស្ថាប័នដូចគ្នា ។

ការតែងតាំងសមាសភាពដែលត្រូវផ្លាស់ប្តូរ ត្រូវធ្វើដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

## ប្រការ៧. –

គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវអនុវត្តការងាររបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានតម្លាភាព ស្របតាមចក្ខុវិស័យ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល ។

អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានភារកិច្ចជួយសម្រួលរាល់សេវាលេខាធិការក្នុងការអនុវត្តការងារ និងការរៀបចំកិច្ចប្រជុំផ្សេងៗ ដល់គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព ។

ប្រការ ៨. –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ដូចប្រការ ២
- គ្រប់ក្រសួង ស្ថាប័ន